ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អន្លង់កំណាប់

## រយៈពេល០៣ ឆ្នាំ (២០១៣ - ២០១៥)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | អន្លង់កំណាប់ |
| ភូមិ | : | កោះច្បារ |
| ឃុំ | : | កោះខ្មែរ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អន្លង់កំណាប់

## រយៈពេល០៣ ឆ្នាំ (២០១៣ - ២០១៥)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | អន្លង់កំណាប់ |
| ភូមិ | : | កោះច្បារ |
| ឃុំ | : | កោះខ្មែរ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អន្លង់កំណាប់

## រយៈពេល០៣ ឆ្នាំ (២០១៣ - ២០១៥)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | អន្លង់កំណាប់ |
| ភូមិ | : | កោះច្បារ |
| ឃុំ | : | កោះខ្ញែរ |
| ស្រុក | : | សំបូរ |
| ខេត្ត | : | ក្រចេះ |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**......១

**២-អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**......២

ក- ប្រជាសាស្ត្រ......២

ខ-មុខរបរ......២

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**......២

ក-ទីតាំង......២

ខ-ដែននេសាទ......៣

គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស......២

ឃ-ធនធានជលផល......៣

**៤-ការធ្វើនេសាទ**......៣

ក-អ្នកនេសាទ......៣

ខ-ឧបករណ៍នេសាទ......៣

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ......៤

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**......៥

ក-ទស្សនវិស័យ......៥

ខ-គោលបំណង......៥

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍......៦

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ......៦

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍......៧

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ......៧

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត......៨

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ......៩

គ៦-ផែនការផ្សព្វផ្សាយ......១០

គ៧-ផែនការបណ្តុះបណ្តាល......១១

គ៨-ផែនការចំណូលថវិកា......១២

គ៥-ផែនការអភិវឌ្ឍវារីវប្បកម្ម......១៣

ឃ.ផែនការយុទ្ធសាស្ត្រ......១៤

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ......១៥

-តារាងកម្មវិធីការងារ......១៨

-តារាងឧបសម្ព័ន្ធ......

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ** ............ ១

**២-អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម** ............ ២

ក- ប្រជាសាស្ត្រ ............ ២

ខ-មុខរបរ ............ ២

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍** ............ ២

ក-ទីតាំង ............ ២

ខ-ដែននេសាទ ............ ៣

គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស ............ ៣

ឃ-ធនធានជលផល ............ ៣

**៤-ការធ្វើនេសាទ** ............ ៣

ក-អ្នកនេសាទ ............ ៤

ខ-ឧបករណ៍នេសាទ ............ ៣

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ............ ៥

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ** ............ ៥

ក-ទស្សនវិស័យ ............ ៥

ខ-គោលបំណង ............ ៥

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៦

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ ............ ៦

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ ............ ៧

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ ............ ៧

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត ............ ៨

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ ............ ១០

គ៦-ផែនការផ្សព្វផ្សាយ ............ ១១

គ៧-ផែនការបណ្តុះបណ្តាល ............ ១២

គ៨-ផែនការចំណូលថវិកា ............ ១២

គ៩-ផែនការកែលំអរដែននេសាទ ............ ១៣

គ១០-ផែនការអភិវឌ្ឍវារីវប្បកម្ម ............ ១៣

ឃ.ផែនការយុទ្ធសាស្ត្រ ............ ១៤

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ ............ ១៥

-តារាងកម្មវិធីការងារ ............ ១៨

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទ**អន្លង់កំណាប់** ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ដោយអង្គការ CAA/Oxfam Australia បន្ទាប់មកអង្គការ WWF បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០១១ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២។

សហគមន៍នេសាទ**អន្លង់កំណាប់** មានទីតាំងស្ថិតនៅក្នុងភូមិកោះច្បារ ឃុំកោះខ្មែរ ស្រុកសំបូរ ខេត្តក្រចេះ ដែលមានសមាជិកសរុបចំនួន ១០០ នាក់ ស្រីចំនួន ០៧ នាក់ និងមានគណៈកម្មការចំនួន ០៩ នាក់ ស្រីចំនួន ០២ នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ២២០ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

១- **អង្គការ** CAA/Oxfam Australia

- បានបង្កើតកន្លែងអភិរក្សសហគមន៍នេសាទ និងដាក់ស្លាកសញ្ញាចំនួន ០៥ ស្លាក
- បានបង្កើតក្រុមល្បាតសហគមន៍នេសាទ
- ធនាគារស្រូវ ធនាគារក្របី ក្រុមសន្សំប្រាក់
- កសិកម្មចំរុះ ចិញ្ចឹមសត្វ ដាំបន្លែ ពេទ្យសត្វភូមិ គណៈកម្មការគ្រោះមហន្តរាយភូមិ
- សាងសង់សាលារៀន ផ្ទះគ្រូ
- គម្រោងអនាម័យទឹកស្អាត បង្គន់ អនាម័យចំរុះ។

២- **រដ្ឋបាលជលផល**

- ផ្តល់កាណូតល្បាតចំនួន០១គ្រឿង បច្ចុប្បន្នមានការខូចខាតត្រូវជួសជុលឡើងវិញទើបអាចដំណើរការបាន។
- ស្លាកសញ្ញាលើក្បូនឬស្សីចំនួន ០៥ ស្លាក។

៣- **អង្គការ** CRDT

- ជួយការងារចិញ្ចឹមមាន់។

៤- **អង្គការ** WWF

- ជួយរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ
- បានជួយរៀបចំឯកសារដើម្បីចុះបញ្ជីសហគមន៍នេសាទដូចជា បញ្ជីឈ្មោះសមាជិក ផែនទីសហគមន៍ កិច្ចព្រមព្រៀង បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងសហគមន៍នេសាទ ។ល។

នៅមុនពេលបង្កើតសហគមន៍នេសាទ តែងតែមានបទល្មើសនេសាទកើតមាននៅក្នុងសហគមន៍នេសាទ និងបណ្តាឱ្យធនធានជលផលមានការថយចុះជាលំដាប់ ។ ប៉ុន្តែបន្ទាប់ពីបានបង្កើតសហគមន៍មក គណៈកម្មការសហគមន៍បានសហការជាមួយប៉ូលីសប៉ុស្តិ៍ អាជ្ញាធរភូមិ ឃុំ ស្រុក ជលផល និងឆ្មាំទន្លេចុះល្បាតនិង បង្ក្រាបបទល្មើសធ្វើឱ្យបទល្មើសនេសាទមានការថយចុះ និងធនធានជលផលមានការកើនឡើងវិញ ។

ទន្ទឹមនឹងនេះ ក៏នៅមានបទល្មើសនេសាទពីអ្នកខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទនៅកន្លែងអភិរក្ស

ជាពិសេសនៅពេលយប់ ។ ដោយសហគមន៍នេសាទមានការខ្វះខាតប្រេងសម្រាប់ចាក់កាណូតចុះយាមល្បាតឱ្យបានទៀងទាត់ កាណូតចាស់ទ្រុឌទ្រោមមិនអាចដំណើរការបាន ខ្វះស្នាក់សម្រាប់បំពេញការងារ ខ្វះសំភារៈសម្រាប់ចុះល្បាត ។ ម៉្យាងវិញទៀត គណៈកម្មការសហគមន៍ នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ ហើយសមាជិកសហគមន៍នេសាទក៏នៅពុំទាន់មានការយល់ដឹង និងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំផងដែរ ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ១.២០០ នាក់ ប្រុសចំនួន ៦៤០ នាក់ ស្រី ៥៦០ នាក់ ក្នុងនោះជនជាតិខ្មែរ ១០០%

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៤ នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ០៥ នាក់ ស្រី ០២ នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៧ នាក់ ស្រី ០៨ នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ០២ នាក់ ស្រី ០១ នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ០២ នាក់ ស្រី ០១ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៩៣ នាក់ ស្រី ៦១ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ១៨៧ នាក់ ស្រី ៩៤ នាក់ មធ្យមសិក្សា ៤៩ នាក់ ស្រី ២៧ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សា ៧ នាក់ ស្រី ១ នាក់ ។

ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

-ធ្វើស្រែវស្សាចំនួន ២២០ គ្រួសារ ទំហំ ២៨៨ ហិកតា

-ធ្វើនេសាទចំនួន ២២០ គ្រួសារ

-ធ្វើចំការចំនួន ៤០ គ្រួសារ ទំហំ ០៧ ហិកតា ( ដាំដំឡូង ២០% , ពោតសណ្តែក ១០ %)

- ធ្វើកម្មការនៅពេលទំនេរពីការងារធ្វើស្រែចំនួន ៣០ %

-ធ្វើជាងផ្ទះចំនួន ០៥ គ្រួសារ

-លក់ដូរចំនួន ១១ គ្រួសារ

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

ក-ទីតាំង

កន្លែងនេសាទសហគមន៍ **អន្លង់កំណប់** ស្ថិតនៅតាមដងទន្លេមេគង្គលើ មានទំហំ ៣៧១,៦៩ ហិកតា និងមាន

និយាមការដូច មានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់នឹងភូមិកំពង់ព្នៅ

-ខាងត្បូងទល់នឹងភូមិជើងពាធ

-ខាងកើតទល់នឹងភូមិកោះច្បារ

-ខាងលិចទល់នឹងភូមិកំពង់រទេះ ឃុំបឹងចារ។

ខ-ដែននេសាទ

កន្លែងនេសាទសហគមន៍អន្លង់កំណប់ ស្ថិតនៅតាមដងទន្លេមេគង្គ ដែលមានអន្លង់ កោះ និងព្រៃលិចទឹកដុះនៅតាមមាត់ច្រាំងទន្លេ និងនៅតាមកោះ ។

គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស

-អន្លង់អភិរក្សកោះច្បារ ទំហំ ១៣,២២ ហិកតា

-អន្លង់អភិរក្សកោះចាន់ ទំហំ ៨ ហិកតា ។

ឃ-ធនធានជលផល

- ប្រភេទត្រី:

ត្រីរៀល ក្អែក ប្រាកណ្តុរ ឈ្វាត ភ្លី ឆ្លាំង ឆ្កោក គ្រុំ កន្ធនដី ខ្យា ត្រនេល អំបុង ព្រលូង រលកស ឆ្ពិ កាហែ ចង្វែង រ៉ស់ អណ្តែង រមាស ក្លាំងហាយ កែស ប្រា ខ្លា ឆ្ដូញ ខ្ទឹង ដំរី កញ្ចុះ ចង្វារ ស្លឹកឫស្សី ឫសចេក ខ្សាន ក្រាញ់ ឆ្ពោង ស្លាត ស្រកាក្តាម គល់ព្រិច ព្រួល ប្រម៉ា ពុកមាត់ឆ្មារ ដងដាវ ក្អុកក្រពអណ្តាតឆ្កែ កញ្ជ្រូក ឆ្ដោរ ក្រពាត់ សណ្តាយ ក្រាយ ត្រសក់ គល់រាំង សារិកាកែវ ខ្នាន់ កន្រ្ទប់ កន្ទ្រង់ប្រេង កំភ្លាញ កន្ធរ ផ្ទក់ ប៉ាវ៉ា ក្អែកពូក ប៉ាស៊ីអ៊ី។

-ប្រភេទវារីសត្វ:

បង្កង កំពិស អណ្តើក គ្រកួត កន្ធាយ ល្មិច ខ្យង បបែល ពស់ព្រលិត សម្លាប់កង្កែប កង្កែប ក្តាម ខ្ចៅ លាស គ្រុំ ននោងរវឹង ចាក់ច្រែង ខ្យា ។

-ប្រភេទព្រៃលិចទឹក:

ដើមរ៉ៃ ទន្លា រាំង អញ្ចោង អណ្តែង អញ្ចោ ត្រស់ ស្តី ព្រីង ឃ្លា ឃ្លេ បន្លាយូន ល្វា ប៉ាង ជ្រោយ ស្រួយក្របៅ បបុស សង្កែ កប្រឹង ញ៉ ស្បូវ ចេកទុំ មាន គ្រែង ។

## ៤-ការធ្វើនេសាទ

ក-អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន ១០០ នាក់ ស្រី ០៧ នាក់។

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៤២០ នាក់ ស្រី ១០ នាក់។
-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ៣០ នាក់ ស្រី ០៨ នាក់។

## ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ១៥០ | ប្រវែង ៥ ម ក្រឡា ០,០២ ម | មករា ដល់ មិថុនា |
| លប | លប | ២០ | មុខ ១ ម បណ្តោយ ១,៧ ម | មករា ដល់ មិថុនា |
| ចាន់ | ចាន់ | ១០ | មុខ ០,៥ ម កម្ពស់ ១,២ ម | មិថុនា ដល់ ធ្នូ |
| សន្ទូចរនង | សាង(៥០ផ្លែ) | ២០ | ផ្លែលេខ ១០-១២ | មករា ដល់ ធ្នូ |
| មង | ត្បូង (៤០ម៉ែត្រ) | ២៣០ | ០,០២ ម- ០,០៩ ម | មករា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ០៥ ទូក | ៥០០-១.០០០ គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៤០ គ្រឿង | ៥០០-១.០០០ គីឡូក្រាម | ៥ សេះ - ៧ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| ប៉ោង | ប៉ោង | ៣០ | មុខ ០,៤ ម បណ្តោយ ០,៩ ម | មិថុនា ដល់ ធ្នូ |
| មង | ត្បូង (៨០ម៉ែត្រ) | ៨០ | ០,៩ ម- ០,១៣ ម | មករា ដល់ ធ្នូ |
| សន្ទូចរនង | សាង(១០០ផ្លែ) | ៣០ | ផ្លែលេខ ៩-១២ | មករា ដល់ មិថុនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៥០០ គីឡូក្រាម | ៥ សេះ- ១៣ សេះ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧០ គីឡូក្រាម | ៣០គីឡូក្រាម | ១០០ គីឡូក្រាម |

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**

## ក-ទស្សនៈវិស័យ

សហគមន៍នេសាទ **អន្លង់កំណាប់** មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និង ចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ខ-គោលបំណង

-ចូលរួមគ្រប់គ្រងកន្លែងនេសាទសហគមន៍**អន្លង់កំណាប់** ។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចំរុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

*គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ*

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

គោលបំណង: - ដើម្បីកំណត់ចំនួនឧបករណ៍នេសាទក្នុងសហគមន៍ឱ្យបានសមស្រប ជៀសវាងការធ្វើនេសាទហួសកម្រិតផលស្តុក ។
- ដើម្បីឱ្យសមាជិកសហគមន៍នេសាទ និងអ្នកនេសាទមកពីក្រៅសហគមន៍ធ្វើនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ទីតាំង និងពេលវេលានេសាទ។

ផលរំពឹងទុក: - ត្រីមេពូជ និងសត្វជ្រោគត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។
- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | សកម្មភាព | គម្រោងថវិកា($) | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|---|---|
| | | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់<br>១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ<br>១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | ២០០$ ក្នុង១ឆ្នាំ | មករា ដល់មិថុនា | សំណាញ់ | ប្រវែង ៥ ម ក្រឡា ០,០២ ម | ១៥០ វង់ | |
| | | | | លប | មុខ ១ ម បណ្តោយ ១,៧ ម | ២០ លប | |
| | | | មិថុនាដល់ធ្នូ | ចាន់ | មុខ ០,៥ ម កម្ពស់ ១,២ ម | ១០ ចាន់ | |
| | | | មករា ដល់ ធ្នូ | សន្ទូចរនង | ផ្លែលេខ ១០-១២ | ២០ សាង | សាង(៥០ ផ្លែ) |
| | | | | មង | ក្រឡា ០,០២ ម- ០,០៩ ម | ២៣០ ត្បូង | ត្បូង (៤០ម៉ែត្រ) |

គោលបំណង: - ដើម្បីបង្ហាញអ្នកនេសាទក្នុងសហគមន៍ និងក្រៅសហគមន៍ឱ្យបានដឹងពីទីតាំងកន្លែងអភិរក្សត្រីមេពូជ និងអភិរក្សសត្វផ្សោត ។
- ដើម្បីការពារត្រីមេពូជ និងសត្វផ្សោតនៅក្នុងសហគមន៍។

ផលរំពឹងទុក: - ត្រីមេពូជ និងសត្វផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។
- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | សកម្មភាព | គម្រោងថវិកា($) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សកោះច្បារ អន្លង់អភិរក្សកោះចាន់ | ១៣,២២៨ | ដាក់ក្បូនឬស្សីស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | ១០០ | ០១.០១.២០១៣ | ៣០.០៦.២០១៣ | ក្បូនឬស្សីត្រូវដាក់រៀងរាល់ឆ្នាំរយៈពេល ៣ ឆ្នាំ |
| | | បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | ៤០០ | ០១.០២.២០១៣ | ៣០.០២.២០១៣ | |

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ

គោលបំណង: - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទមានឧបករណ៍ សំភារៈគ្រប់គ្រាន់ក្នុងការចុះល្បាត និងទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទ។
- ដើម្បីឱ្យសហគមន៍នេសាទមានទីស្នាក់ការដើម្បីធ្វើការងាររដ្ឋបាល ប្រជុំការងារ ការទំនាក់ទំនង និងរក្សាទុកសំភារៈ និងឯកសារផ្សេងៗ ។

ផលរំពឹងទុក: - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។
- សហគមន៍នេសាទមានទីស្នាក់ការសម្រាប់ទំនាក់ទំនងការងារ និងប្រចាំការ។

| | | | ថវិកា($) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣.១--ពង្រឹងការងារល្បាតក្នុងសហគមន៍ | អាវពោង | ៥ អាវ | ១,៥០០ | ០១.០១.២០១៣ | ៣០.០១.២០១៣ | |
| | អាវភ្លៀង | ៦ អាវ | | | | |
| | ភ្លើងហ្វាដាក់តាមកាណូត | ៤ | | | | |
| | វិទ្យុទាក់ទង | ៤ | | | | |
| | អាគុយ | ១ | | | | |
| | ឯកសណ្ឋានអាវ និងមួកសម្រាប់ល្បាត | ២០ | | | | |
| | ស្បែកជើងកវែង | ២០ | | | | |
| | ម៉ាស៊ីនថត | ១ | | | | |
| | អង្រឹង | ២០ | | | | |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | ទីស្នាក់ការទំហំ ៤មX៦ម | ១ | ២.០០០ | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | ទូកទំហំ ៩ ម x ០,៨ ម | ១ | ១,២០០ | ០១.០១.២០១៣ | ៣០.០១.២០១៣ | |

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត

គោលបំណង: - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទ ប្រជុំបូកសរុបលទ្ធផលដែលបានអនុវត្ត លើកបញ្ហាផ្សេងដែលបានជួបប្រទះ លើកផែនការអនុវត្តបន្ត ។

- ធ្វើរបាយការណ៍ពីលទ្ធផលការងារ ការលំបាក ការងាយស្រួល ទៅអាជ្ញាធរឃុំ ស្រុក ខណ្ឌរដ្ឋបាលជលផលដើម្បីជួយដោះស្រាយ ។

ផលរំពឹងទុក: - សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព ។

| សកម្មភាព | អ្នកចូលរួម | គម្រោងថវិកា($) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្ត<br>- ឆ្នាំទន្លេ | ៣៥$/ខែ<br>១ឆ្នាំ=៣៥x១២=<br>៤២០$ | ២៤.០១.២០១៣ | ២៤.១២.២០១៥ | ប្រជុំរៀងរាល់ខែ រយៈពេល ៣ ឆ្នាំ |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្ត<br>- ឆ្នាំទន្លេ<br>- សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | ៦០០$ ក្នុង១ឆ្នាំ | ១២.១២.២០១៣ | ១២.១២.២០១៥ | មួយឆ្នាំម្តង |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្ត<br>- ឆ្នាំទន្លេ | ៥០០$ ក្នុង១ឆ្នាំ | ២៥.១២.២០១៣ | ៣០.១២.២០១៥ | ៣ឆ្នាំម្តង |

| | | | | | |
|---|---|---|---|---|---|
| | - សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | | | | |

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គោលបំណង: - ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព ។

- សហគមន៍នេសាទមានមធ្យោបាយសម្រាប់ទប់ស្កាត់បទល្មើស ។

ផលរំពឹងទុក: - សហគមន៍នេសាទមានការយាមល្បាតទៀងទាត់។

- បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ ។

ផែនការចុះទប់ស្កាត់បទល្មើសនេសាទត្រូវបានរៀបចំដូចខាងក្រោម:

| សកម្មភាព | តម្រូវការសំភារៈ | គម្រោងថវិកា($) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៥.១-ចុះល្បាតចំនួន ១០ ដង ក្នុង១ ខែនៅរដូវប្រាំង (១០ ដង×៨ ខែX៤ លីត្រ=៣២០លីត្រ) | - ប្រេងសាំងចំនួន ៣២០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៨ លីត្រ | ៤២០ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ<br>- ឆ្មាំទន្លេ | ០១.០១.២០១៣ | ៣០.០៨.២០១៣ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា (៥ ដង×៤ ខែX៤ លីត្រ=៨០ លីត្រ) | - ប្រេងសាំងចំនួន ៨០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៤ លីត្រ | ១១០ | | ០១.០៩.២០១៣ | ៣០.១២.២០១៣ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |

គោលបំណង: ដើម្បីឱ្យសមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងពីឯកសារផ្សេងៗ របស់សហគមន៍ និង ប្រកាស អនុក្រឹត្យ និងច្បាប់ផ្សេងដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ផលរំពឹងទុក: សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តឱ្យមាន ប្រសិទ្ធភាព។

ផែនការផ្សព្វផ្សាយច្បាប់ជលផលត្រូវបានរៀបចំឡើងដូចខាងក្រោម :

| សកម្មភាព | តម្រូវការ | គម្រោងថវិកា($) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | -ឯកសារផ្សព្វផ្សាយ<br>-គ្រូបង្គោល | ៣៥០$ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល សមាជិកសហគមន៍នេសាទ | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀង ប្រកាសស្តីពីការចុះបញ្ជីសហគមន៍នេសាទនិងផែនទីកន្លែងនេសាទសហគមន៍ | | ៣៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៣៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោត និងបរិស្ថាន | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១.២០១៣ | |

គោលបំណង: ផ្តល់ចំណេះដឹងពីការងាររដ្ឋបាល ការងារធ្វើផែនការ ការងារដឹកនាំ និងនីតិវិធីកសាងឯកសារនានាដល់គណៈកម្មការសហគមន៍នេសាទ។

លទ្ធផលរំពឹងទុក: គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។

ផែនការផ្សព្វផ្សាយច្បាប់ជលផលត្រូវបានរៀបចំឡើងដូចខាងក្រោម :

| សកម្មភាព | តម្រូវការ | គម្រោងថវិកា($) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | -ឯកសារបណ្តុះបណ្តាល<br>-គ្រូបណ្តុះបណ្តាល | ៣៥០$ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ក្រុមល្បាត | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសនេសាទបឋម | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |

គ៨-ផែនការចំណូលថវិកា

គោលបំណង: ដើម្បីប្រមូលថវិកាពីសមាជិកមកប្រើប្រាស់សម្រាប់ការងារគ្រប់គ្រងសហគមន៍។

លទ្ធផលរំពឹងទុក: សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។

ផែនការចំណូលថវិកាត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ៨.១-ភាគទានពីសមាជិកសហ | ប្រមូលភាគទានពីសមាជិកដែលចូលថ្មី | ០១.០១.២០១៣ | ០១.១២.២០១៥ | ១០០.០០០រៀល | ១.០០០រៀល/នាក់ |

| | | | | | |
|---|---|---|---|---|---|
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | ប្រមូលភាគទានប្រចាំឆ្នាំពីសមាជិក | ០១.០១.២០១៣ | ០១.១២.២០១៥ | ៣៤២.០០០ រៀល | ១.០០០ រៀល/នាក់ រយៈពេល៣ឆ្នាំ |

គ៩-ផែនការកែលំអរដែននេសាទ

សំគាល់: ដោយកន្លែងនេសាទសហគមន៍ស្ថិតនៅតាមដងទន្លេមេគង្គពុំមានផែនការត្រូវកែលំអរឡើយ ។

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវកែលំអរ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

កំណត់សំគាល់: ទីតាំងសហគមន៍ស្ថិតនៅក្នុងតំបន់ស្នូលទី៣ ក្នុងឃុំកំពង់ចាម ដែលកំណត់ដោយអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ពុំអនុញ្ញាតឱ្យធ្វើ វារីវប្បកម្មបែ ឬសិងក្នុងតំបន់ស្នូលនៅរដូវប្រាំង ម៉្យាងវិញទៀតនៅតំបន់នេះ ជាប្រភេទដីមិនគត់ទឹកនៅរដូវប្រាំង ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រី | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| | | | | | |

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានៈសមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បី ទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់។

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក្ខ | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។<br>- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។ | ២០០$ ក្នុង ១ឆ្នាំ | អង្គការនានា រដ្ឋបាលជលផល ថវិកាសហគមន៍ | ០១.០១.២០១៣ | ៣០.០១.២០១៥ | |
| | ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | ០១.០១.២០១៣ | ៣០.០១.២០១៥ | |
| | ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | | | | ០១.០១.២០១៣ | ៣០.១២.២០១៥ | |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | ២.១-ដាក់ក្បូនឬស្សីស្លាកសញ្ញាសំគាល់ កន្លែងអភិរក្សចំនួន ៥ ស្លាក | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។<br>- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។ | ៥០០$ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ៣០.០៦.២០១៣ | រៀងរាល់ឆ្នាំ |
| | ២.២-បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | | | | ០១.០២.២០១៣ | ៣០.០២.២០១៣ | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ | ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។<br>- សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារនិងប្រចាំការ។ | ១,៥០០$ | អង្គការនានា រដ្ឋបាលជលផល | ០១.០២.២០១៣ | ៣០.០២.២០១៣ | |
| | ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | | ២.០០០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | | ១,២០០$ | | ០១.០១.២០១៣ | ៣០.០១.២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គណៈកម្មការ និងក្រុមល្បាត | សហគមន៍ | ការគ្រប់គ្រងមានប្រសិទ្ធភាព។ -បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្ត ។ | ៧២០$ | អង្គការនានា រដ្ឋបាលជលផល ថវិកាសហគមន៍ | ២៤.០១.២០១៣ | ២៤.១២.២០១៥ | ប្រចាំរៀងរាល់ខែ |
| | ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | | ៦០០$ | | ១២.១២.២០១៣ | ១២.១២.២០១៥ | មួយឆ្នាំម្តង |
| | ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៥០០$ | | ០១.១១.២០១៥ | ៣០.១២.២០១៥ | បីឆ្នាំម្តង |
| គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ៥.១-ចុះល្បាតចំនួន ១០ ដង ក្នុង១ខែនៅរដូវប្រាំង | -សហគមន៍នេសាទមានការយាមល្បាតទៀងទាត់។ -បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ ។ | ៣២៥$ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ៣០.០៨.២០១៣ | |
| | ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែនៅរដូវវស្សា | | ២០០$ | | ០១.០៩.២០១៣ | ៣០.១២.២០១៣ | |
| គ៦-ផែនការផ្សព្វផ្សាយ | ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តឱ្យមានប្រសិទ្ធភាព។ | ២៥០$ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍ និងផែនទីកន្លែងនេសាទសហគមន៍ | | ២៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ២៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ២៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គ្រប់គ្រងនិងការពារសត្វផ្សោតនិងបរិស្ថាន | | ២៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ២៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| គ៧-ផែនការបណ្តុះបណ្តាល | ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។ | ២៥០ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ២៥០ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ២៥០ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ២៥០ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | | ២៥០ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| គ៨-ផែនការចំណូលថវិកា | ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។ | ២០ | ថវិកាសហគមន៍ | ០១.០១.២០១៣ | ០១.១២.២០១៥ | |
| | ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | | ២០ | | ០១.០១.២០១៣ | ០១.១២.២០១៥ | |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ** ..... ១

**២-អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម** ..... ២

ក- ប្រជាសាស្ត្រ ..... ២

ខ-មុខរបរ ..... ២

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍** ..... ២

ក-ទីតាំង ..... ២

ខ-ដែននេសាទ ..... ២

គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស ..... ៣

ឃ-ធនធានជលផល ..... ៣

**៤-ការធ្វើនេសាទ** ..... ៣

ក-អ្នកនេសាទ ..... ៣

ខ-ឧបករណ៍នេសាទ ..... ៣

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ..... ៤

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ** ..... ៥

ក-ទស្សនវិស័យ ..... ៥

ខ-គោលបំណង ..... ៥

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៦

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ ..... ៦

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ ..... ៧

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ ..... ៧

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត ..... ៨

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ ..... ១០

គ៦-ផែនការផ្សព្វផ្សាយ ..... ១១

គ៧-ផែនការបណ្តុះបណ្តាល ..... ១២

គ៨-ផែនការចំណូលថវិកា ..... ១៣

គ៩-ផែនការកែលំអរដែននេសាទ ..... ១៤

គ១០-ផែនការអភិវឌ្ឍវារីវប្បកម្ម ..... ១៤

ឃ.ផែនការយុទ្ធសាស្ត្រ ..... ១៥

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ ..... ១៦

-តារាងកម្មវិធីការងារ ..... ២០

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍វាលព្រលូងលួងចិត្ត រយៈពេល០៣ឆ្នាំ (២០១៣ ដល់ ២០១៥)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។<br>- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់។ | ២០០$ ក្នុង ១ឆ្នាំ | អង្គការនានា រដ្ឋបាលជលផល ថវិកាសហគមន៍ | ០១.០១.២០១៣ | ៣០.០១.២០១៥ | |
| | ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | ០១.០១.២០១៣ | ៣០.០១.២០១៥ | |
| | ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | | | | ០១.០១.២០១៣ | ៣០.១២.២០១៥ | |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | ២.១-ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | - ត្រីមេពូជ និងផ្សោតត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍។<br>- ការនេសាទនៅកន្លែងអភិរក្សត្រូវបានហាមឃាត់។ | ៥០០$ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ៣០.០៦.២០១៣ | រៀងរាល់ឆ្នាំ |
| | ២.២-បោះបង្គោលព្រំប្រទល់សហគមន៍ចំនួន ៤បង្គោល | | ៤០០$ | | ០១.០២.២០១៣ | ៣០.០២.២០១៣ | |
| | ២.៣-ដាក់បូស៊ីម៉ង់ចំនួន ៤០ លូ | | ២.០០០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហ | ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្ត | ១.៥០០$ | អង្គការនានា រដ្ឋបាលជលផ | ០១.០២.២០១៣ | ៣០.០២.២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គមន៍នេសាទ | | ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។ | | ល | | | |
| | ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | - សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារ និងប្រចាំការ។ | ២.០០០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | | ១.២០០$ | | ០១.០១.២០១៣ | ៣០.០១.២០១៣ | |
| គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត | ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព។<br>-បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្ត ។ | ៣៥$/ខែ<br>១ឆ្នាំ=៣៥X ១២=៤២០ $ | អង្គការនានា រដ្ឋបាលជលផល ថវិកាសហគមន៍ | ២៤.០១.២០១៣ | ២៤.១២.២០១៥ | ប្រជុំរៀងរាល់ខែ |
| | ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | | ៦០០$ ក្នុង១ឆ្នាំ | | ១២.១២.២០១៣ | ១២.១២.២០១៥ | មួយឆ្នាំម្តង |
| | ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៥០០$ | | ០១.១១.២០១៥ | ៣០.១២.២០១៥ | បីឆ្នាំម្តង |
| គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ៥.១-ចុះល្បាតចំនួន ១០ ដង ក្នុង១ខែនៅរដូវប្រាំង( ៨ ខែ) | -សហគមន៍នេសាទមានការយាមល្បាតទៀងទាត់។<br>-បទល្មើសនេសាទនៅក្នុងសហគមន៍ត្រូវបានថយចុះ ។ | ៤២០$ ក្នុងរដូវប្រាំង ក្នុង១ឆ្នាំ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ៣០.០៨.២០១៣ | |
| | ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា( ៤ ខែ) | | ១១០$ ក្នុងរដូវវស្សា ក្នុង១ឆ្នាំ | | ០១.០៩.២០១៣ | ៣០.១២.២០១៣ | |
| គ៦-ផែនការផ្សព្វផ្សាយ | ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគ | ៣៥០$ | អង្គការនានា រដ្ឋបាលជលផ | ០១.០១.២០១៣ | ០១.០២.២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍ និងផែនទីកន្លែងនេសាទសហគមន៍ | មន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តឱ្យមានប្រសិទ្ធភាព។ | ៣៥០$ | ល | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៣៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតនិងបរិស្ថាន | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| គ៧-ផែនការបណ្តុះបណ្តាល | ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។ | ៣៥០$ | អង្គការនានា រដ្ឋបាលជលផល | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០$ | | ០១.០១.២០១៣ | ០១.០២.២០១៣ | |
| | ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៧.៤-បណ្តុះបណ្តាលអំពីការតាមដាននិងវិភាគគុណភាពទឹក | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |
| | ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជល | | ៣៥០$ | | ០១.១២.២០១៣ | ៣០.១២.២០១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ផលបឋម | | | | | | |
| គ៨-ផែនការចំណូលថវិកា | ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។ | ២០ | ថវិកាសហគមន៍ | ០១.០១.២០១៣ | ០១.១២.២០១៥ | |
| | ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | | ២០ | | ០១.០១.២០១៣ | ០១.១២.២០១៥ | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៣ | | | | | | | | | | | | ២០១៤ | | | | | | | | | | | | ២០១៥ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាត ទំហំ ពេល វេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | |
| ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១-ដាក់ក្បូនឫស្សីស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៦ ស្លាក | — | — | — | — | — | — | → | | | | | — | — | — | — | — | — | — | → | | | | | — | — | — | — | — | — | — | → | | | | | → |
| ២.២-បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | | | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | | | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| |
|---|
| ៣.២-សាងសង់ទស្នាកការសហគមន៍ |
| ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ |
| **គ៤-ផែនការប្រជុំគណៈ កម្មការ និងក្រុមល្បាត** |
| ៤.១-ប្រជុំប្រចាំខែរបស់គណៈ កម្មការសហគមន៍ |
| ៤.២-រៀបចំមហាសន្និបាត សហគមន៍នេសាទប្រចាំឆ្នាំ |
| ៤.៣-រៀបចំផែនការគ្រប់គ្រង ឡើងវិញ |
| **គ៥-ផែនការចុះ ល្បាតទប់ស្កាត់ បទល្មើសនេសាទ** |
| ៥.១-ចុះល្បាតចំនួន ១០ ដង ក្នុង១ ខែនៅរដូវប្រាំង |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង ១ ខែ នៅរដូវវស្សា |
| គ៦-ផែនការផ្សព្វផ្សាយ |
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងហគមន៍ នេសាទ |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជី សហគមន៍និងផែនទីកន្លែង នេសាទសហគមន៍ |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការ |

| | |
|---|---|
| គ្រប់គ្រងកន្លែងនេសាទសហគមន៍ | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | → |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់ គ្រប់គ្រងនិងការពារសត្វផ្សោតនិង បរិស្ថាន | → |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | → |
| គ៧-ផែនការបណ្តុះ បណ្តាល | |
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | → |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | → |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | → |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដានវិភាគគុណភាពទឹក | → |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និង ការកសាងសំណុំរឿងបទល្មើសជលផលបឋម | → |
| គ៨-ផែនការចំណូល ថវិកា | |
| ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | → |

| | |
|---|---|
| ៨.២-ភាគទានរបស់សមាជិក<br>សហគមន៍នេសាទប្រចាំឆ្នាំ | |

លេខ : ០៤......ដ.ក៣

<u>បានឃើញនិងបញ្ជូនមក</u>

លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

" <u>ដើម្បីពិនិត្យនិងសម្រួល</u>"

កាំពី ថ្ងៃទី ខែ ឆ្នាំ២០១៣

នាយផ្នែករដ្ឋបាលជលផលកាំពី

លេខ :.................

<u>បានឃើញនិងបញ្ជូនមក</u>

លោកនាយផ្នែករដ្ឋបាលជលផលកាំពី

" <u>ដើម្បីពិនិត្យនិងសម្រួល</u>"

កោះខ្មែរ ថ្ងៃទី ខែ ឆ្នាំ២០១៣

មេឃុំកោះខ្មែរ

ស៊ុក_សាវី

លេខ :.................

<u>បានឃើញនិងបញ្ជូនមក</u>

លោកមេឃុំកោះខ្មែរ

" <u>ដើម្បីពិនិត្យនិងសម្រួល</u>"

កោះច្បារ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៣

មេភូមិកោះច្បារ

ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៣

ប្រធានគណៈកម្មការសហគមន៍

នេសាទអន្លង់កំណប់

លេខ :០៤៤......ជក.ខែ

<u>បានឃើញនិងបញ្ជូនមក</u>

លោកនាយអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ

" <u>ដើម្បីពិនិត្យនិងសម្រួល</u>"

ក្រចេះ ថ្ងៃទី ខែ ០២ ឆ្នាំ២០១៣

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

សៀន គិន

លេខ :០១៣.អជជ

<u>បានឃើញនិងគោរពជូន</u>

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" <u>ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ</u>"

កំពង់ចាម .ថ្ងៃទី ១៩ ខែ ០២ឆ្នាំ២០១៣

នាយអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ

លេខ :......៤១៥

<u>បានឃើញ និងឯកភាព</u>

រាជធានីភ្នំពេញ .ថ្ងៃទី ខែ ឆ្នាំ២០១៣

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

អនុប្រធានរដ្ឋបាលជលផល

កាំង_ឃីម